# នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ** : ០០៣/០៧-០៩-២០០៩-អវតក/កសចស (អ.ប.ជ៣៥)

**ដាក់ទៅ** : សហចៅក្រមស៊ើបអង្កេត

**ថ្ងៃដាក់** : ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១

**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញាអន្តរជាតិ

**ភាសាដើម** : អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 20-Apr-2021, 08:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** សាធារណៈ

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយ កសចស:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

## សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅកាន់សហចៅក្រមស៊ើបអង្កេត សុំឲ្យបញ្ជូនសំណុំរឿង០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង

---

**អ្នកដាក់ឯកសារ:**

លោកស្រី Brenda J. HOLLIS

**សហព្រះរាជអាជ្ញាអន្តរជាតិ**

**អ្នកទទួលឯកសារ:**

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Michael BOHLANDER

**សហមេធាវី មាស មុត:**

អាង ឧត្តម

Michael KARNAVAS

**ចម្លងជូន:**

លោកស្រី ជា លាង

**សហព្រះរាជអាជ្ញាជាតិ**

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង ០០៣:**

## I. សេចក្តីផ្តើម

1. បន្ទាប់ពីការចេញសេចក្ដីពិចារណាក្នុងសំណុំរឿង ០០៣[1] របស់អង្គបុរេជំនុំជម្រះ ("អ.ប.ជ") រួចមក សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") ស្នើសុំដោយគោរពឱ្យសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") រួមគ្នា ឬចៅក្រមណាម្នាក់ក្នុងចំណោមចៅក្រមទាំងពីរ ចាត់វាល់វិធានការរដ្ឋបាល ដែលចាំបាច់ទាំងអស់ ដើម្បីបង្គាប់ឱ្យផ្នែកគ្រប់គ្រងតុលាការ ("CMS") បញ្ជូនសេចក្ដីពិចារណានេះ រួមទាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[2] ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ") និង អនុញ្ញាតឱ្យ អ.ជ.ស.ដ ចូលមើលសំណុំរឿង ដែលនៅសេសសល់តាមប្រព័ន្ធអេឡិចត្រូនិក។

2. ស.ព.អ ធ្វើសំណើនេះដើម្បីអនុវត្តការព្រមព្រៀងជាឯកច្ឆន្ទរបស់ចៅក្រម អ.ប.ជ ដែលថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសំណុំរឿង ០០៣ មានសុពលភាព។ អនុលោមតាមវិធាន ៧៧(១៤) នៃ វិធានផ្ទៃក្នុង[3]("វិធាន")វាគឺជាភារកិច្ចរបស់ ស.ច.ស ក្នុងការបន្តកិច្ចនីតិវិធីស្របតាមសេចក្ដីសម្រេច របស់ អ.ប.ជ ដោយបញ្ជូនសំណុំរឿង ០០៣ ទៅកាន់ អ.ជ.ស.ដ ជាបន្ទាន់។ ស.ព.អ សន្និដ្ឋានថា ចាំបាច់ត្រូវមានការបញ្ជូនយ៉ាងឆាប់រហ័សមួយ អនុលោមតាមមាត្រា ១២(២) នៃកិច្ចព្រមព្រៀង អ.វ.ត.ក[4] មាត្រា ៣៣ និង មាត្រា ៣៥ថ្មី នៃច្បាប់ អ.វ.ត.ក[5] និងវិធាន ២១(១) និង (៤)[6]

[1] **D266/27 & D267/35** សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ ("សេចក្ដីពិចារណា")។

[2] **D267** ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")។

[3] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) ដែលត្រូវបានកែប្រែនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធាន")។

[4] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក") មាត្រា ១២(២) ("អង្គជំនុំជម្រះវិសាមញ្ញ ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ["ICCPR"] ដែលកម្ពុជា គឺជាភាគីហត្ថលេខីដែរ។")។ ICCPR មាត្រា ១៤(៣)(គ) ("ក្នុងការសម្រេចសេចក្ដីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ [...] (គ) ត្រូវបានជំនុំជម្រះ*ដោយឥតពន្យារពេលហួសហេតុ*") (គូសបញ្ជាក់បន្ថែម))។

[5] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ បូកជាមួយច្បាប់វិសោធនកម្មដែលបានប្រកាសឱ្យប្រើ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ("ច្បាប់ អ.វ.ត.ក") មាត្រា ៣៣ថ្មី ("អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ និងឆាប់រហ័ស ទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និងមាន ការការពាឱ្យបានត្រឹមត្រូវ

ដើម្បីធានាដល់សិទ្ធិ និងផលប្រយោជន៍របស់ភាគីទាំងអស់នៃរឿងក្តី០០៣ និងដើម្បីធានាឲ្យបាននូវភាពឆាប់រហ័ស ភាពប្រាកដប្រជាផ្នែកច្បាប់ និងកិច្ចការរដ្ឋបាលត្រឹមត្រូវរបស់អង្គជំនុំជម្រះ។

## II. ប្រវត្តិនីតិវិធីពាក់ព័ន្ធ

3. នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេត ("ស.ច.ស.អ") បានចេញដីកាដំណោះស្រាយ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ") ដែលបានចោទប្រកាន់ មាស មុត អំពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ និងការរំលោភក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ និងឲ្យបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះ[7]។ នៅថ្ងៃដដែល សហចៅក្រមស៊ើបអង្កេតជាតិ ("ស.ច.ស.ជ") បានចេញដីកាដំណោះស្រាយ ("ដីកាលើកលែងចោទប្រកាន់") ទម្លាក់ចោលរាល់ការចោទប្រកាន់ទាំងអស់ប្រឆាំង មាស មុត ផ្អែកលើមូលដ្ឋានថា គាត់មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")[8]។

4. នៅថ្ងៃទី៥ និងទី៨ ខែមេសា ឆ្នាំ២០១៩ បណ្តឹងឧទ្ធរណ៍ចំនួនបីជំទាស់ទៅនឹងដីកាដំណោះស្រាយ

ចំពោះជនរងគ្រោះ") មាត្រា ៣៥ថ្មី ("នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា [...] គ. ត្រូវបានទទួលការជំនុំជម្រះដោយគ្មានការអូសបន្លាយ")។

[6] វិធាន ២១ ("គោលការណ៍ជាសារវន្ត។ ១. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យ *ការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទជនជាប់ចោទ និង ជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់* និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង ។ ក្នុងបរិបទនេះ៖ ក-ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយ*ត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ* [...]។ គ-អង្គជំនុំជម្រះវិសាមញ្ញ ត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី [...]។ ៤. ការសម្រេចសេចក្តីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ត្រូវធ្វើការជំនុំជម្រះ*ក្នុងរយៈពេលមួយសមស្រប*។") (គូសបញ្ជាក់បន្ថែម)។

[7] **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ EN 01596603-11, FR 01621343-52, KH 01600889-98។

[8] **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ("ដីកាលើកលែងចោទប្រកាន់") កថាខណ្ឌ ៤២៧-៤៣០។

ទាំងនេះបានដាក់ទៅកាន់ អ.ប.ជ ដោយសហព្រះរាជអាជ្ញាជាតិ ស.ព.អ និង មាស មុត[9]។

5. នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ អ.ប.ជ បានចេញសេចក្តីពិចារណារបស់ខ្លួន[10] ដែលនៅក្នុងនោះ សុពលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលបញ្ជូន មាស មុត ទៅជំនុំជម្រះត្រូវបានគាំទ្រដោយចៅក្រមទាំងប្រាំរូបនៃ អ.ប.ជ[11]។ លើសពីនេះទៀត ចៅក្រមអន្តរជាតិបានសន្និដ្ឋានថា ដីកាលើកលែងចោទប្រកាន់ត្រូវទុកជាមោឃៈ និងគ្មានសុពលភាព ដោយមានវិការៈទាំងអង្គសេចក្តី[12] និងទាំងនីតិវិធី[13]។ សេចក្តីសម្រេចជាឯកច្ឆន្ទរបស់អង្គជំនុំជម្រះសម្រេចថា "អនុលោមតាមវិធាន ៧៧(១៤)

[9] ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងទៅនឹង ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (D266) ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩។ ឯកសារ **D267/3** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩។ ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩។

[10] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា។

[11] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា យោបល់របស់ចៅក្រម ប្រាក់ គឹម សាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី កថាខណ្ឌ ១១៥ ("ន័យដូចចែងក្នុងវិធាន ៧៧(១៣) ខាងលើ ដីកាដំណោះស្រាយទាំងពីរមានតម្លៃស្មើគ្នា ត្រូវតម្កល់ទុកជាបានការដូចគ្នា *មានសុពលភាព*ដូចគ្នា។" (គូសបញ្ជាក់បន្ថែម)) យោបល់របស់ចៅក្រម Olivier Beauvallet និងចៅក្រម Kang Jin Baik ("យោបល់របស់ចៅក្រមអន្តរជាតិ") កថាខណ្ឌ២៨៤ ("ទោះបីជា មានការចេញដីកាដំណោះស្រាយក្នុងពេលជាមួយគ្នាក្តី ក៏ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានអានុភាពដែរ ដោយសារតែដីកានេះមានសុពលភាពជាសារធាតុ ហើយមានអនុលោមភាពជាមួយក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក") កថាខណ្ឌ៣៣៩-៣៤០ (បានតម្កល់ការសម្រេចរបស់ ស.ច.ស.អ ថា មាស មុត ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ហើយហេតុដូច្នេះ ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក) កថាខណ្ឌ ៣៤២-៣៤៣ (បានសន្និដ្ឋានថា មានការសម្រេចជាឯកច្ឆ័ន្ទ*តាមព្រឹត្តន័យ* នៅក្នុងរឿងក្តីនេះ៖ ទោះបីជា មានសំអាងហេតុខុសគ្នា ចៅក្រមជាតិ និងចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានសម្រេចស្របគ្នាថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព និងតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះជាឯកច្ឆ័ន្ទ)។

[12] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ១១៩, ២២៦-២៥០, ២៨៤ (បានតម្កល់មូលដ្ឋាន ខ និង គ នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ និងបានសម្រេចថា សំណុំរឿង០០៣ មានដីកាលើកលែងចោទប្រកាន់មិនពេញលេញ ដែលមិនអើពើចំពោះភ័ស្តុតាងរយៈពេលប្រាំពីរឆ្នាំ ដែលបានដាក់ក្នុងសំណុំរឿងចាប់តាំងពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ និងការចោទប្រកាន់ផ្នែកអង្គហេតុជាច្រើន ដែលប្តឹងមក ស.ច.ស.ជ យ៉ាងត្រឹមត្រូវដោយ ស.ព.អ។ ចៅក្រមអន្តរជាតិបានសម្រេចថា ដីកាលើកលេងចោទប្រកាន់ដែលមិនពេញលេញនេះគឺគ្មានសុពលភាពនៅក្នុងអត្ថន័យនៃវិធាន ៦៧ និងត្រូវទុកជាមោឃៈ និងគ្មានសុពលភាពដោយសារតែហេតុផលមួយនេះប៉ុណ្ណោះ។)។

[13] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ២២៥-២៦២, ២៨៤ (បានសម្រេចថា ដីកាលើកលែងចោទប្រកាន់គឺទុកជាមោឃៈ និងគ្មានសុពលភាព ដោយហេតុថាដីកានេះត្រូវបានចេញផ្ទុយទៅនឹងគោលការណ៍នៃការបន្តការស៊ើបអង្កេត និងការចោទប្រកាន់ ដែលមាននៅក្នុងក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក។

នៃវិធានផ្ទៃក្នុង ក្រឡាបញ្ជីនៃ [អ.ប.ជ] ត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់ [ស.ចៅ.ស] សហព្រះរាជអាជ្ញា និងភាគីនានា"។ អ.ប.ជ បានបញ្ជាក់ជាឯកច្ឆន្ទថា ដំណាក់កាលនីតិវិធីជាបន្តបន្ទាប់ទៀត ក្រោយពីការចេញសេចក្តីពិចារណានេះ គឺមានចែងក្នុងវិធាន ៧៧(១៣) និង (១៤)[14]។

## III. ច្បាប់ជាធរមាន

6. វិធាន ១(២) ចែងក្នុងផ្នែកពាក់ព័ន្ធថា៖

ជាពិសេស លើកលែងតែមានចែងផ្សេងពីនេះ ការយោងនៅក្នុងវិធានផ្ទៃក្នុងនេះចំពោះពាក្យសហចៅក្រមស៊ើបអង្កេត សំដៅទៅដល់សហចៅក្រមស៊ើបអង្កេតទាំងពីរ ដែលធ្វើការសម្រេចចិត្តរួមគ្នា និងចៅក្រមស៊ើបអង្កេតណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ ទោះបីដោយផ្ទាល់ ឬតាមរយៈតំណាង [...]។

7. វិធាន ៦៩ ចែងថា៖

១. នៅពេលមានបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបញ្ជូនសំណុំរឿងទៅក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះ ដូចមានចែងក្នុងវិធាន ៧៧។

២. នៅពេលដែលគ្មានបណ្តឹងឧទ្ធរណ៍ សហចៅក្រមស៊ើបអង្កេតត្រូវបិទសំណុំរឿងដោយមានបោះត្រាលើសំណុំរឿង និង ៖

ក) ប្រសិនបើមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបញ្ជូនសំណុំរឿងទៅក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីកំណត់កាលបរិច្ឆេទសវនាការ។

ខ) ប្រសិនបើមានដីកាលើកលែងការចោទប្រកាន់ សំណុំរឿងត្រូវបានរក្សាទុកក្នុងបណ្ណសារ ក្រោយពីផុតរយៈពេលធ្វើបណ្តឹងឧទ្ធរណ៍។

៣. ការដាក់ពាក្យប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ មិនរារាំងអង្គជំនុំជម្រះសាលាដំបូង និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការមើលសំណុំរឿង ក្នុងគោលបំណងត្រៀមរៀបចំជាមុនសម្រាប់ការជំនុំជម្រះទេ។

[14] ឯកសារ **D266/27** & **D267/35** សេចក្តីពិចារណា សេចក្តីសម្រេច EN 01666984, FR 01667141, KH 01667329។

8. វិធាន ៧៧(១៣) ចែងថា៖

១៣. សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឲ្យមានសម្លេងគាំទ្រជាវិជ្ជមានពីចៅក្រម៤(បួន)រូបយ៉ាងតិច។ សេចក្តីសម្រេចនេះត្រូវបិទផ្លូវតវ៉ា។ ប្រសិនបើសម្លេងភាគច្រើនដែលតម្រូវមិនអាចរកបានទេ សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្ររបស់អង្គបុរេជំនុំជម្រះត្រូវអនុវត្តដូចខាងក្រោម៖ [...]

ខ-ក្នុងករណីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ប្រសិនបើមិនអាចរកសម្លេងភាគច្រើនដែលតម្រូវបាននោះទេ អង្គបុរេជំនុំជម្រះ ត្រូវសម្រេចប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង ដោយឈរលើមូលដ្ឋានដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត។

9. វិធាន ៧៧(១៤) ចែងថា៖

សេចក្តីសម្រេចទាំងអស់ស្ថិតនៅក្នុងវិធាននេះ រួមទាំងគំនិតជំទាស់ផងត្រូវមានសំអាងហេតុ និងចុះហត្ថលេខាដោយចៅក្រមទាំងនោះ។ សេចក្តីសម្រេចនេះត្រូវជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និង ភាគីដទៃទៀតដោយក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះ។ *សហចៅក្រមស៊ើបអង្កេតត្រូវបន្តកិច្ចនីតិវិធី ជាបន្ទាន់ស្របតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ*[15]។

10. វិធាន ៧៩(១) ចែងថា៖

អង្គជំនុំជម្រះសាលាដំបូង*ទទួលបណ្តឹង* ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ឬ តាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ[16]។

11. ច្បាប់ជាធរមានដែលនៅសេសសល់ ត្រូវបានបង្ហាញនៅក្នុងកថាខណ្ឌពាក់ព័ន្ធ។

## IV. សេចក្តីសន្និដ្ឋាន

*ស.ច.ស ត្រូវតែបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូងជាបន្ទាន់*

12. នៅក្នុងសេចក្តីពិចារណារបស់ខ្លួន ចៅក្រម អ.ប.ជ ទាំងប្រាំរូប បានសន្និដ្ឋានថា ដីកាបញ្ជូនរឿងទៅ

[15] គូសបញ្ជាក់បន្ថែម។

[16] គូសបញ្ជាក់បន្ថែម។

ជំនុំជម្រះមានសុពលភាព[17] បង្កើតបានជាសេចក្តីសម្រេចមួយដែលមានសំឡេងគាំទ្រភាគច្រើនលើសលុប នៅក្នុងអត្ថន័យនៃវិធាន ៧៧(១៣)[18]។ អនុលោមតាមវិធាន ៧៧(១៣) និង ៧៩(១)[19] ដូច្នេះ អ.ជ.ស.ដ ត្រូវបានប្តឹងឲ្យទទួលយករឿងក្តី ០០៣ ដោយស្វ័យប្រវត្តិ នៅពេលចេញសេចក្តីពិចារណាទាំងនោះ[20]។

[17] *សូមមើល យោងខាងលើ* ជើងទំព័រ១១។

[18] ស.ព.អ កត់សម្គាល់ថា សូម្បីតែក្នុងករណីដែល ស.ច.ស ធ្វើការបកស្រាយសេចក្តីពិចារណាផ្សេងពីនេះក៏ដោយ ដោយហេតុថាដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនត្រូវបានបដិសេធដោយសំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ អនុលោមតាមវិធាន ៧៧(១៣)(ខ) និង ៧៩(១) ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះបានប្តឹងជាស្វ័យប្រវត្តិទៅ អ.ជ.ស.ដ ហើយកាតព្វកិច្ចរបស់ ស.ច.ស ក្នុងការបញ្ជូនសេចក្តីពិចារណា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងដែលនៅសេសសល់ ក៏ត្រូវកើតមានឡើងក្នុងវិធីដូចគ្នានេះដែរ។

[19] វិធាន ១(២) ចែងថា "ការយោងនៅក្នុងវិធានផ្ទៃក្នុងនេះចំពោះពាក្យសហចៅក្រមស៊ើបអង្កេត សំដៅទៅដល់សហចៅក្រមស៊ើបអង្កេតទាំងពីរ ដែលធ្វើការសម្រេចចិត្តរួមគ្នា និងចៅក្រមស៊ើបអង្កេតណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ"។ ហេតុដូច្នេះ វិធាន ៧៩(១) អនុវត្តទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលចេញដោយ ស.ច.ស តែម្នាក់ ដូចក្នុងករណីបច្ចុប្បន្ននេះ។ *សូមមើលផងដែរ* កថាខណ្ឌ ១៦ *យោងខាងក្រោម*។

[20] ស.ព.អ ដឹងអំពីការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") ថា អ.ជ.ស.ដ មិនមានយុត្តាធិការទេប្រសិនបើមិនមានសំណុំរឿងបញ្ជូនមកខ្លួនទេនោះ (រឿងក្តី ០០៤/២-**E004/2/1/1/2** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាព សំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ កថាខណ្ឌ ៤៩-៥០, ៥២, ៥៧, ៧១) ប៉ុន្តែយល់ស្របគ្នាជាមួយនឹងចៅក្រមអន្តរជាតិនៃ អ.ប.ជ នៅក្នុងការសន្និដ្ឋានរបស់ខ្លួនថា សេចក្តីសន្និដ្ឋាននេះផ្អែកលើកំហុសផ្នែកច្បាប់ធ្ងន់ធ្ងរនៃការប្រៀបប្រដូច និងភ្ជាប់កិច្ចរដ្ឋបាលក្នុងការបញ្ជូនសំណុំរឿង ជាមួយនឹងឧបសគ្គផ្នែកយុត្តាធិការ ដែលរារាំង អ.ជ.ស.ដ មិនឲ្យធ្វើសកម្មភាព (ឯកសារ **D266/27** & **D267/35** សេចក្តីពិចារណា យោបល់របស់ចៅក្រមអន្តរជាតិ ជើងទំព័រ ៥៩៤)។ សេចក្តីសន្និដ្ឋានរបស់ អ.ជ.ត.ក មិនបានផ្អែកលើឯកសារសំអាងផ្លូវច្បាប់ណាមួយឡើយ និងផ្ទុយទៅនឹងវិធានផ្ទៃក្នុង រួមទាំងវិធាន ៧៩(១) ដែលចែងថា "អង្គជំនុំជម្រះសាលាដំបូង*ទទួលបណ្តឹង* ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះ"។ ដូចដែលចៅក្រមអន្តរជាតិបានគូសបញ្ជាក់ បុរេលក្ខខណ្ឌរដ្ឋបាលដាច់ខាតក្នុងទំហំបែបនេះ មិនអាចគ្រាន់តែទាញការសន្និដ្ឋានផ្ទុយទៅនឹងគោលការណ៍ *la compétence de la competence* បានទេ (*សូមមើលឧទាហរណ៍* រឿងក្តី *Tadić*, IT-94-1-AR72 អង្គជំនុំជម្រះតុលាការកំពូល សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី សុំដាក់បណ្តឹងសាទុក្ខបន្ទាន់បង្គំ លើយុត្តាធិការ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ ១៨-១៩) ហើយវាស្ថិតនៅក្នុងអំណាចរបស់ អ.ជ.ស.ដ ក្នុងការស្នើសុំរឿងក្តី ០០៤/២ ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា ចាំបាច់ត្រូវសម្រេចលើបណ្តឹងរបស់ខ្លួនផ្ទាល់។ បញ្ហាសំខាន់ដូចជាការបញ្ជូនរឿងក្តីទៅជំនុំជម្រះ មិនគួរត្រូវបានកំណត់ដោយអសកម្មរបស់តុលាការទេ។ ជាងនេះទៀត គោលជំហររបស់ អ.ជ.ត.ក ផ្ទុយទៅនឹងការអនុវត្តរបស់ អ.វ.ត.ក ក្នុងរឿងក្តី ០០១ និង ០០២។ *សូមមើល* រឿងក្តី ០០២-**E9** ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ សេចក្តីផ្តើម ត្រង់ EN 00635755, FR 00635761, KH 00635748 (បានកត់សម្គាល់ថា អ.ជ.ស.ដ បានទទួលសំណុំរឿង អនុលោមតាមសាលដីកាលើបណ្តឹងឧទ្ធរណ៍ ដែលបានចេញដោយ អ.ប.ជ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១) និងត្រង់កថាខណ្ឌ ២

13. ផលវិបាកផ្នែករដ្ឋបាលនៃការទទួលបណ្តឹងរបស់ អ.ជ.ស.ដ គឺថា សេចក្តីពិចារណា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងដែលនៅសេសសល់ ត្រូវតែបញ្ជូនទៅ អ.ជ.ស.ដ សម្រាប់ការចាប់ផ្តើមការជំនុំជម្រះ។ អនុលោមតាមក្របខណ្ឌនីតិវិធីរបស់ អ.វ.ត.ក ការទទួលខុសត្រូវចំបងសម្រាប់ការបញ្ជូននេះគឺធ្លាក់ទៅលើ ស.ច.ស។ ដូចដែលបានកត់ត្រានៅក្នុងផ្នែកសម្រេចសេចក្តីជាឯកច្ឆ័ន្ទ[21] ស.ច.ស ត្រូវបានជូនដំណឹងអំពីសេចក្តីពិចារណាទាំងនោះ[22] ហើយអនុលោមតាមវិធាន ៧៧(១៤) ត្រូវតែ "បន្តកិច្ចនីតិវិធីជាបន្ទាន់ ស្របតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ"។ អាស្រ័យហេតុដូច្នេះ ស.ច.ស អាច[23] និងត្រូវតែអនុវត្តវិធាន ៦៩(២)(ក) *តាមការកែប្រែចាំបាច់* (*mutatis*

(បានកត់សម្គាល់ថា អ.ប.ជ បានបញ្ជូនសំណុំរឿងទៅកាន់ក្រឡាបញ្ជី អ.ជ.ស.ដ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១)។ ដីកាបង្គាប់នេះបញ្ជាក់ច្បាស់ថា បណ្តឹង និងការបញ្ជូនសំណុំរឿង គឺជាកិច្ចដាច់ដោយឡែកពីគ្នា និងថាបណ្តឹង មិនមែនការបញ្ជូនសំណុំរឿងទេ ដែលផ្តល់យុត្តាធិការទៅឱ្យ អ.ជ.ស.ដ។ គោលជំហរនេះត្រូវបានបញ្ជាក់នៅក្នុងសាលក្រមក្នុងរឿងក្តី ០០២ ចំនួនពីរ ដែលបានសម្រេចថា អ.ជ.ស.ដ បានទទួលសំណុំរឿងក្រោយពេលសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាដំណោះស្រាយ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ (រឿងក្តី ០០២-**E313** សាលក្រមរឿងក្តី ០០២/០១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ២៣។ រឿងក្តី ០០២-**E465** សាលក្រមរឿងក្តី ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ កថាខណ្ឌ ៣៣)។ *សូមមើលផងដែរ* វិធាន ៦៩(៣)។ រឿងក្តី ០០១-**E5** សេចក្តីជូនដំណឹងពីកិច្ចប្រជុំរៀបចំសវនាការ និងដីកាបង្គាប់ឱ្យភាគីដាក់ឯកសារបន្ថែម ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨ សេចក្តីផ្តើម ត្រង់ EN 00250117, FR 00250626, KH 00250110 (បានកត់សម្គាល់ថា អ.ជ.ស.ដ បានទទួលបណ្តឹងអនុលោមតាមសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដែលបានចេញដោយ អ.ប.ជ នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨)។ រឿងក្តី ០០១-**D99/3/5** សេចក្តីសម្រេចលើសំណើរបស់អង្គជំនុំជម្រះសាលាដំបូងសុំការអនុញ្ញាតពិនិត្យសំណុំរឿង ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨ កថាខណ្ឌ៧ (បន្ទាប់ពីបានស្នើសុំចូលមើលសំណុំរឿងមុន អ.ជ.ស.ដ បានទទួលស្គាល់ថា "ការចូលមើលសំណុំរឿងនេះ មិនមែនជាការទទួលសំណុំរឿងជាលក្ខណៈផ្លូវការនោះទេ រហូតដល់ពេលមានការចេញសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយនេះសិន")។

[21] ឯកសារ **D266/27** & **D267/35** សេចក្តីពិចារណា ផ្នែកសម្រេចសេចក្តី EN 01666984, FR 01667141, KH 01667329។

[22] *សូមមើល* សេចក្តីជូនដំណឹងតាមសារអេឡិចត្រូនិក ពីមន្ត្រីទទួលបន្ទុកសំណុំរឿង ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ ម៉ោង ៤:១៤ នាទីល្ងាច មានចំណងជើងថា "[ដាក់ដោយ អ.ប.ជ] ឯកសារថ្មី៖ សំណុំរឿង ០០៣ – សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ" ដោយមានរាយឈ្មោះជាអ្នកទទួល គឺចៅក្រមនៃ ស.ច.ស គឺចៅក្រម យូ ប៊ុនឡេង និង ចៅក្រម Michael Bohlander ក៏ដូចជាក្រឡាបញ្ជី ក.ស.ច.ស ឈ្មោះ ឆាយ ច័ន្ទលីដា ផងដែរ។

[23] អ.ប.ជ បានបញ្ជាក់ថា ខ្លួនមានសិទ្ធិអំណាចផ្តាច់មុខលើសំណុំរឿងភ្លាមៗបន្ទាប់ពីការចេញដីកាដំណោះស្រាយ លើកលែងតែមុខងាររដ្ឋបាល ដូចជាក្នុងករណីនេះ ដែលមានចែងយ៉ាងច្បាស់នៅក្នុងក្របខណ្ឌគតិយុត្តិ អ.វ.ត.ក។ *សូមមើល* ឯកសារ **D266/27** & **D267/35** សេចក្តីពិចារណា យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ១៣២ រឿងក្តី ០០៤/១-**D308/3/1/20** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាង ហេតុ)

*mutandis*) ដើម្បីបង្គាប់ឲ្យផ្នែកគ្រប់គ្រងតុលាការ បញ្ជូនសេចក្តីពិចារណា (ដែលអាចរកបានជាសាធារណៈ) និង ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានតម្កល់ ទៅកាន់ក្រឡាបញ្ជីនៃ អ.ជ.ស.ដ និងអនុញ្ញាតឲ្យ អ.ជ.ស.ដ ចូលមើលសំណុំរឿងដែលនៅសេសសល់តាមអេឡិចត្រូនិក។

14. តាមពិត អ.ប.ជ បានបញ្ជាក់យ៉ាងស៊ីចង្វាក់ថា អង្គបុរេជំនុំជម្រះបំពេញមុខងាររបស់សភាស៊ើបសួររបស់កម្ពុជា[24] ហើយនីតិវិធីដែលបានគូសបញ្ជាក់នៅទីនេះ ស្របគ្នាទាំងស្រុងជាមួយនឹងនីតិវិធីដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ("CCCP")[25] ទាក់ទងនឹងបញ្ហានោះ។ មាត្រា ២៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[26] ចែងថា ក្រោយពីការបិទបញ្ចប់ការស៊ើបអង្កេតរបស់ សភាស៊ើបសួរ បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមាត្រា ២៤៧ ដល់ ២៥០[27] ត្រូវអនុវត្ត ពាក់ព័ន្ធនឹងការបិទបញ្ចប់ការស៊ើបអង្កេតតាមផ្លូវតុលាការដោយចៅក្រមស៊ើបសួរ។ ជាពិសេស មាត្រា ២៥០ បញ្ជាក់ថា នៅពេលដែលចៅក្រមស៊ើបអង្កេតចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ គាត់ត្រូវបញ្ជូនសំណុំរឿងនោះជាបន្ទាន់ទៅកាន់ប្រធានតុលាការ ដើម្បីកំណត់កាលវិភាគសម្រាប់ការជំនុំជម្រះ[28]។

15. ស.ព.អ សន្និដ្ឋានថា សំណុំរឿង ០០៣ ត្រូវតែបានបញ្ជូនទៅ អ.ជ.ស.ដ ជាបន្ទាន់ ស្របតាមបទប្បញ្ញត្តិនៃវិធានផ្ទៃក្នុង និង ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងដើម្បីធានាបាននូវការអនុវត្តតាម

ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ("សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ") កថាខណ្ឌ ៣៣។ រឿងក្តី ០០៤/២-**D360/3** សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំការកោសលុប និងការចាត់ វិធានការ បណ្តោះអាសន្ន ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៨ កថាខណ្ឌ ៦, ១២-១៣ និងផ្នែកសម្រេចសេចក្តី EN 01584812, KH 01585158-9។

[24] *សូមមើលជាឧទាហរណ៍* រឿងក្តី ០០១-**D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ ៤១។ រឿងក្តី ០០៤/១-**D308/3/1/20** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២២។ រឿងក្តី ០០៤/២-**D359/24** & **D360/33** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៩ ("សេចក្តីពិចារណា") កថាខណ្ឌ ៤៤។ *សូមមើលផងដែរ* ឯកសារ **D266/27** & **D267/35** សេចក្តីពិចារណា យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ១២៩-១៣០, ១៣២។

[25] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៧ ("CCCP")។

[26] CCCP មាត្រា ២៨២ កថាខណ្ឌទី៣។

[27] CCCP មាត្រា ២៤៧-២៥០ (មាត្រា ២៤៧ (ដីកាដំណោះស្រាយ) មាត្រា ២៤៨ (ការប្រគល់វត្ថុដែលចាប់យកឲ្យទៅម្ចាស់ដើមវិញ) មាត្រា ២៤៩ (សេចក្តីសម្រេចនៃដីកាដំណោះស្រាយទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ) មាត្រា ២៥០ (ការបញ្ជូនដីកាបើកសវនាការជំនុំជម្រះ))។

[28] CCCP មាត្រា២៥០ ("ប្រសិនបើចៅក្រមស៊ើបសួរសម្រេចចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងជាបន្ទាន់ទៅប្រធានតុលាការ ដើម្បីកំណត់ពេលសវនាការជំនុំជម្រះ")។

"គោលការណ៍រួមដែលថា កិច្ចដំណើរការនីតិវិធី អ.វ.ត.ក ចាំបាច់ត្រូវគោរពតាមលក្ខខណ្ឌតម្រូវនៃនីត្យានុកូលភាព ភាពត្រឹមត្រូវយុត្តិធម៌ និងប្រសិទ្ធិភាព តាមក្របខណ្ឌគតិយុត្តិ អ.វ.ត.ក" ដើម្បីសម្រេចបាន "យុត្តិធម៌ព្រហ្មទណ្ឌប្រកបដោយប្រសិទ្ធភាព"[29]។

*សហចៅក្រមស៊ើបអង្កេតម្នាក់ អាចបំពេញកិច្ចតែឯងដើម្បីបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង*

16. ស.ព.អ រំលឹកឡើងវិញនូវគោលការណ៍នៃការបន្តកិច្ចស៊ើបសួរ ឬការចោទប្រកាន់ ដែលត្រូវបានបញ្ជាក់នៅក្នុងក្របខ័ណ្ឌច្បាប់ អ.វ.ត.ក[30] ដើម្បីចៀសវៀងការជាប់គាំងផ្នែកនីតិវិធី[31] និងដើម្បីធានានូវយុត្តិធម៌ប្រកបដោយប្រសិទ្ធភាព[32]។ អនុលោមតាមគោលការណ៍នោះ ស.ច.ស ម្នាក់អាចបំពេញកិច្ចតែឯង ដើម្បីបញ្ជូនសេចក្តីពិចារណា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងដែលនៅសេសសល់ទៅកាន់ អ.ជ.ស.ដ[33]។ "វិធាននៃផ្ទៃក្នុង មិនត្រឹមតែប្រមើលជាមុនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេតធ្វើសេចក្តីសម្រេចតែម្នាក់ឯង ជាតុលាការដែលត្រូវបានបង្កើតឡើងយ៉ាងត្រឹមត្រូវ"[34] ជាពិសេសក្នុងករណីដែលសហការីរបស់គាត់បានដកខ្លួនចេញពីការ

[29] រឿងក្តី ០០៣/២-**D359/24** & **D360/33** សេចក្តីពិចារណា កថាខណ្ឌ ១០៩ (ជាឯកច្ឆ័ន្ទ)។ កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១២(២)។ ច្បាប់ អ.វ.ត.ក មាត្រា ៣៣ថ្មី។ វិធានផ្ទៃក្នុង ២១(១), (៤)។ *សូមមើលយោងខាងលើ* កថាខណ្ឌ ២។

[30] *សូមមើល* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៥(៤) និង ច្បាប់ អ.វ.ត.ក មាត្រា ២៣ថ្មី ដែលឯកសារទាំងពីរនេះចែងថា ក្នុងករណីដែលមានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត "ការស៊ើបអង្កេតនោះត្រូវដំណើរការទៅមុខទៀត" លើកលែងតែ ស.ច.ស ទាំងពីរ ឬ ស.ច.ស ណាម្នាក់ក្នុងចំណោមអ្នកទាំងពីរនេះបញ្ជូនការខ្វែងយោបល់គ្នារបស់ខ្លួនទៅ អ.ប.ជ។

[31] **D266/27** & **D267/35** សេចក្តីពិចារណា កថាខណ្ឌ ៩០, ៩៧ (ជាឯកច្ឆ័ន្ទ)។ រឿងក្តី ០០៤/២-**D359/24** & **D360/33** សេចក្តីពិចារណា កថាខណ្ឌ ១១១ (ជាឯកច្ឆ័ន្ទ)។

[32] **D266/27** & **D267/35** សេចក្តីពិចារណា កថាខណ្ឌ ៩៧ (ជាឯកច្ឆ័ន្ទ)។ រឿងក្តី ០០៤/២-**D359/24** & **D360/33** សេចក្តីពិចារណា កថាខណ្ឌ ១០១, ១១១ (ជាឯកច្ឆ័ន្ទ)។ *សូមមើលផងដែរ* ឯកសារ **D266/27** & **D267/35** សេចក្តីពិចារណាយោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ២៥៨ ("គោលដៅជាគន្លឹះ នៃយន្តការដោះស្រាយការខ្វែងយោបល់គ្នា គឺរាំងភាពជាប់គាំង ដែលបណ្តាលឲ្យកិច្ចដំណើរការនីតិវិធីផុតចេញពីការបញ្ជូនទៅជំនុំជម្រះ")។

[33] វិធាន ១(២) និងការដកស្រង់បន្តបន្ទាប់។

[34] **D128/1/9** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ("សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ស្តីពីការចោទប្រកាន់") កថាខណ្ឌ ៣៤ (ជាឯកច្ឆ័ន្ទ) *ដកស្រង់* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៥(៤)។ ច្បាប់ អ.វ.ត.ក មាត្រា ២៣ថ្មី។ វិធាន ៧២។

បន្តការស៊ើបអង្កេត[35]។ អ.ប.ជ បានសម្រេចថា "កិច្ចព្រមព្រៀង ច្បាប់ អ.វ.ត.ក និងវិធានចែងថា សហចៅក្រមស៊ើបអង្កេតម្នាក់ អាចបំពេញកិច្ចមានសុពលភាពតែម្នាក់ឯងបាន ប្រសិនបើលក្ខខណ្ឌតម្រូវនៃនីតិវិធីនៃការខ្វែងយោបល់គ្នាត្រូវបានបំពេញ"[36] និងក្នុងករណីដែលសកម្មភាពនៅតែស្របគ្នាជាមួយនឹងគោលជំហរស្វ័យប្រវត្តិ "ជាសារវន្ត និងជាកត្តាកំណត់"[37] ដែលជាធាតុផ្សំសំខាន់នៃប្រព័ន្ធគតិយុត្តិរបស់ អ.វ.ត.ក ដែលថា "ការស៊ើបអង្កេតត្រូវតែបន្ត"[38]។

*អភវនីយភាពនៃការកាត់ទោសជនត្រូវចោទរបស់ អ.វ.ត.ក នៅក្នុងតុលាការជាតិនៃប្រទេសកម្ពុជា*

17. ជាចុងក្រោយ ស.ព.អ កត់សម្គាល់ថា អ.ប.ជ បានបញ្ជាក់កន្លងមកអំពីទស្សនៈរបស់ខ្លួនថា តុលាការថ្នាក់ជាតិធម្មតាមានយុត្តាធិការជំនុំជម្រះរឿងក្តីសម័យខ្មែរក្រហម ដែល អ.វ.ត.ក មិនបានទទួលបណ្តឹង[39]។ នៅក្នុងសេចក្តីពិចារណាក្នុងរឿងក្តី ០០៣ ចៅក្រមអន្តរជាតិបានបញ្ជាក់ជំហរនេះឡើងវិញ ដោយបានណែនាំ *ក្នុងចំណោមរឿងផ្សេងទៀត* ឲ្យមានការផ្តួចផ្តើមការចោទប្រកាន់ដោយសហព្រះរាជអាជ្ញាជាតិ និង/ឬសហព្រះរាជអាជ្ញាអន្តរជាតិនៃ អ.វ.ត.ក ចំពោះបុគ្គលណាដែល

[35] រឿងក្តី ០០៤/២-**D359/24** & **D360/33** សេចក្តីពិចារណា កថាខណ្ឌ ១០៥ (ជាឯកច្ឆ័ន្ទ) *ដកស្រង់* រឿងក្តី ០០៤-**D236/1/1/8** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើញត្តិសុំពិចារណាឡើងវិញ និងលុបចោលដីកាកោះ ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១៤ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ស្តីពីដីកាកោះ") កថាខណ្ឌ ៣០។ រឿងក្តី ០០៤-**A122/6.1/3** សេចក្តីសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម សុំព្យួរការអនុវត្តដីកាកោះហៅអ្នកស្រី ឲ្យមកបង្ហាញខ្លួនជាលើកដំបូង ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៤។

[36] សំណុំរឿង ០០៤/២-**D359/24** & **D360/33** សេចក្តីពិចារណា កថាខណ្ឌ ១០៥ (ជាឯកច្ឆ័ន្ទ) *ដកស្រង់* សំណុំរឿង ០០៤/២-**D208/1/1/2** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន ប្រឆាំងដីកាសម្រេចបដិសេធសំណើរបស់គាត់ស្នើសុំព័ត៌មានទាក់ទងនឹងករណីខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ កថាខណ្ឌ១១។ សំណុំរឿង ០០៤-**D236/1/1/8** សាលដីកាលើបណ្តឹងឧទ្ធរណ៍ស្តីពីដីកាកោះ កថាខណ្ឌ ២៤។ ឯកសារ **D128/1/9** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ស្តីពីការចោទប្រកាន់ កថាខណ្ឌ ៣៤ (ជាឯកច្ឆ័ន្ទ)។

[37] **D266/27** & **D267/35** សេចក្តីពិចារណា កថាខណ្ឌ៩៨ (ជាឯកច្ឆ័ន្ទ)។ សំណុំរឿង ០០៤/២-**D359/24** & **D360/33** សេចក្តីពិចារណា កថាខណ្ឌ១១២។

[38] ឯកសារ **D266/27** & **D267/35** សេចក្តីពិចារណា កថាខណ្ឌ ៩៤, ៩៧, ១០០ (ជាឯកច្ឆ័ន្ទ)។ សំណុំរឿង ០០៤/២-**D359/24** & **D360/33** សេចក្តីពិចារណា កថាខណ្ឌ ១០៦, ១១៤, ១១៦-១១៧ (ជាឯកច្ឆ័ន្ទ)។

[39] សំណុំរឿង ០០៤/១-**D308/3/1/20** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ៧៩-៨០ និងផ្នែកសម្រេចសេចក្តី EN 01575165, FR 01575307, KH 01575475-6។ សំណុំរឿង ០០៤/២-**D359/24** & **D360/33** សេចក្តីពិចារណា កថាខណ្ឌ ៥៧-៥៩ និងផ្នែកសម្រេចសេចក្តី EN 01634239-40, FR 01634523-4, KH 01634854-5។

ត្រូវបានសន្និដ្ឋានថា មិនស្ថិតនៅក្នុងយុត្តាធិការផ្តាច់មុខរបស់ អ.វ.ត.ក[40]។ ទោះបីជា ស.ព.អ ឯកភាពទាំងស្រុងថា រាល់រឿងក្តីទាំងអស់ដែលប្តឹងមក អ.វ.ត.ក សមនឹងទទួលបានការចោទប្រកាន់យ៉ាងណាក្តី ក៏គាត់សូមយកឱកាសនេះបញ្ជាក់ថា ផ្អែកលើហេតុផលមួយចំនួន គាត់មិនមានបំណងបន្តការចោទប្រកាន់ជនត្រូវចោទរបស់ អ.វ.ត.ក នៅក្នុងតុលាការធម្មតារបស់កម្ពុជានោះទេ គឺនៅក្នុងករណីទាំងឡាយណាដែលរឿងក្តីរបស់ពួកគេមិនបានបន្ត ឬនឹងមិនបន្តទៅជំនុំជម្រះនៅ អ.វ.ត.ក ហើយគាត់ក៏មិនមានហេតុផលណាដែលនាំឱ្យជឿថា សហការីជាតិរបស់គាត់ ឬអាជ្ញាធរកម្ពុជាដទៃទៀតមានបំណងធ្វើដូច្នោះដែរ។ ហេតុដូច្នេះ គាត់ជំរុញឱ្យ ស.ច.ស កុំរាប់បញ្ចូលភរនីយភាពដែលមានលក្ខណៈទាយស្មានខ្លាំង និងមិនប្រាកដប្រជានេះនៅក្នុងការពិភាក្សារបស់ខ្លួន និងសូមឱ្យបំពេញភារកិច្ចរបស់ខ្លួន ដូចដែលមានចែងយ៉ាងច្បាស់លាស់នៅក្នុងក្របខ័ណ្ឌច្បាប់ អ.វ.ត.ក និងដូចដែលបានរំលឹកខាងលើ។

## V. ដំណោះស្រាយដែលស្នើសុំ

18. សម្រាប់មូលហេតុដូចបានរៀបរាប់ខាងលើ សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើឱ្យសហចៅក្រមស៊ើបអង្កេត រួមគ្នា ឬចៅក្រមណាម្នាក់ក្នុងចំណោមចៅក្រមទាំងពីរ ចាត់រាល់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ ដើម្បីបញ្ជូនជាបន្ទាន់នូវសេចក្តីពិចារណា ដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃរឿងក្តី ០០៣ និងសំណុំរឿងដែលនៅសេសសល់ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ | **លោកស្រី Brenda J HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |

[40] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ១៧០-១៧៦, ៣៤៤។